

# ពង្រឹងអំណាចដល់ក្រុមគោលដៅ

*ប្រជាកសិករធម្មតាមួយក្រុមនៅក្នុងខេត្តស្វាយរៀង មានមោទនភាពចំពោះខ្លួនឯង ពីព្រោះពួកគាត់ទើបតែបានបញ្ចប់ដំណើរការរៀបចំផែនការ និងបង្កើត សហគមន៍កសិកម្ម ដែលជារបស់ខ្លួនឯងផ្ទាល់ ស្របតាមច្បាប់រដ្ឋាភិបាល។ ពិតណាស់ សហគមន៍កសិកម្ម នឹងផ្តល់ប្រយោជន៍ដល់កសិករច្រើនយ៉ាង ក្នុងពេលជាមួយគ្នាដែរ ក៏ផ្តល់ឲ្យកសិករនូវឋានៈស្របច្បាប់មួយ។ ក្នុងនាមជាក្រុមកសិករបញ្ជាក់ថា "សហគមន៍កសិកម្ម គឺជាក្របខ័ណ្ឌស្របច្បាប់សម្រាប់កសិករនៅកម្ពុជា ធ្វើឲ្យពួកយើងមានទំនុកចិត្តចំពោះការងាររបស់យើង និងពេលជាមួយគ្នាដែរ ពួកយើងត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាល"។*

កសិករទាំងនេះ មកពីឃុំមួយក្នុងចំណោមឃុំគោលដៅរបស់គម្រោងអាយស៊ីស៊ី ហ្វាស(អភិវឌ្ឍន៍គ្រួសារ និង សាលារៀន) បានធ្វើទស្សនកិច្ចសហគមន៍កសិកម្មមួយនៅខាងក្រៅឃុំរបស់ពួកគាត់។ ពួកគាត់រំភើបអំពីអ្វីដែលពួកគាត់បានរៀនសូត្រពីសហគមន៍កសិកម្មនេះ ហើយគិតថា ប្រសិនបើពួកគាត់អាចមានសហគមន៍កសិកម្មផ្ទាល់ វានឹងបង្កើតក្របខ័ណ្ឌស្របច្បាប់សម្រាប់កសិករ និងសម្រាប់ក្រុមជួយខ្លួនឯងចំនួន១១ក្រុមនៅក្នុងឃុំពួកគាត់។ នៅពេលត្រឡប់ទៅវិញ ពួកគាត់បានចាប់ផ្តើមស្វែងយល់ពីរបៀបបង្កើតសហគមន៍កសិកម្ម។ កសិករបានស្នើសុំរកការណែនាំពីគម្រោងហ្វាស ពីព្រោះអាយស៊ីស៊ី មានបទពិសោធន៍ក្នុងការបង្កើតសហគមន៍កសិកម្មនៅខេត្តមួយផ្សេងទៀត។

កសិករបានសម្រេចថា គោលបំណង និងមុខងាររបស់សហគមន៍កសិកម្មរបស់ពួកគាត់គឺ៖

- ការជួញដូរផលិតផលកសិកម្ម
- សេវាកម្មសន្សំ
- បណ្តាញ និងទីផ្សារ

មុខងារទាំងបីនេះ មានអត្ថន័យដើម្បីផ្តល់ផលប្រយោជន៍ដល់កសិករនៅមូលដ្ឋានក្នុងឃុំ និងជាពិសេសម្ចាស់ភាគហ៊ុនសហគមន៍កសិកម្ម។ វាមានអត្ថប្រយោជន៍សម្រាប់កសិករ ដែលពួកគាត់អាចទិញទំនិញកសិកម្មពីសហគមន៍កសិកម្មទាបជាង បើប្រៀបធៀបទៅនឹងការទិញពីឈ្មួញកណ្តាល។ កសិករអាចសន្សំប្រាក់ និង/ឬខ្ចីពីសហគមន៍កសិកម្មដោយមានលក្ខខណ្ឌល្អ ជាជាងធ្វើតាមរយៈធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ សហគមន៍កសិកម្ម ផ្ទេរចំណេះដឹងបច្ចេកទេសដល់កសិករដែលពួកគាត់បានរៀនពីអង្គការក្រៅរដ្ឋាភិបាល និងនាយកដ្ឋានរដ្ឋ។ លើសពីនេះទៅទៀត សហគមន៍កសិកម្ម ក៏ជួយកសិករលក់ផលិតផលក្នុងតម្លៃសមរម្យ និងស្ថិតនៅក្រោមលក្ខខណ្ឌត្រឹមត្រូវ។ អត្ថប្រយោជន៍សម្រាប់ម្ចាស់ភាគហ៊ុនដែលទទួលបាន គឺពីប្រាក់ចំណេញរបស់សហគមន៍កសិកម្ម។

មន្ទីរកសិកម្មខេត្តស្វាយរៀង គ្រោងឲ្យមានសហគមន៍កសិកម្មមួយក្នុងឃុំនីមួយៗក្នុងចំណោមឃុំទាំង៨០ក្នុងខេត្តទាំងមូល។ រហូតមកដល់ពេលនេះ សហគមន៍កសិកម្មចំនួន៥២ ត្រូវបានបង្កើតឡើងតាមរយៈរដ្ឋាភិបាល ឬសង្គមស៊ីវិល។ គម្រោងហ្វាស រួមចំណែកដល់ដំណើរការនេះ នៅក្នុងឃុំគោលដៅ ដើម្បីធានាថាសហគមន៍កសិកម្មដែលបានបង្កើតមានរចនាសម្ព័ន្ធរឹងមាំ និងមាននិរន្តរភាពយូរអង្វែង។ លើសពីនេះ គម្រោងហ្វាស ចង់ឃើញដំណើរការ និងមុខងាររបស់សហគមន៍កសិកម្មនៅក្នុងឃុំគោលដៅ មានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់កសិករ។

កាលបរិច្ឆេទ៖ ធ្នូ ២០១៧